Australian Government
Medicare Australia

# ការណែនាំឲ្យស្គាល់ប្រព័ន្ធសុខភាពអូស្ត្រាលី និងមេឌីឃែរអូស្ត្រាលី

# (Introduction to the Australian health system and Medicare Australia)

## ប្រព័ន្ធសុខភាពអូស្ត្រាលី

ប្រព័ន្ធសុខភាពអូស្ត្រាលីត្រូវបានចាត់ទុកយ៉ាងទូលំទូលាយថាជាចំណាត់ថ្នាក់ពិភពលោក បើនិយាយអំពីប្រសិទ្ធភាព និងប្រសិទ្ធផលវិញនោះ។ ប្រព័ន្ធនេះគឺជាការលាយចូលគ្នានូវស្ថាប័នផ្តល់កិច្ចបំរើសុខភាពសាធារណៈ និងវិស័យឯកជន ដោយមានរួមទាំង៖

- រដ្ឋាភិបាលអូស្ត្រាលី – ទទួលខុសត្រូវចំពោះការបង្កើតគោលការណ៍ បទបញ្ញត្តិ និងការផ្តល់ថវិកាជាតិ
- រដ្ឋាភិបាលថ្នាក់រដ្ឋ ដែនដី និងតំបន់ – ទទួលខុសត្រូវចំពោះការផ្តល់ និងការគ្រប់គ្រងកិច្ចបំរើសុខភាពសាធារណៈ និងការរក្សាចំណងទាក់ទងជាមួយស្ថាប័នផ្តល់ការថែទាំសុខភាពភាគច្រើន
- គ្រូពេទ្យឯកជន – មានរួមទាំងគ្រូពេទ្យព្យាបាលជំងឺទូទៅ អ្នកឯកទេស និងគ្រូពេទ្យពិគ្រោះយោបល់ទាំងឡាយ
- អង្គការរកប្រាក់កំរៃ និងមិនរកប្រាក់កំរៃ ព្រមទាំងអង្គការស្ម័គ្រចិត្តនានា។

លោកអ្នកអាចទទួលព័ត៌មានបន្ថែមអំពីប្រព័ន្ធសុខភាពរបស់ប្រទេសអូស្ត្រាលី ពីវ៉ិបសៃរបស់ក្រសួងសុខាភិបាល និងការចូលវ័យចំណាស់ **www.health.gov.au**

## តើមេឌីឃែរអូស្ត្រាលី (Medicare Australia) ជាអ្វី?

មេឌីឃែរអូស្ត្រាលីគឺជាស្ថាប័នមួយរបស់រដ្ឋាភិបាលអូស្ត្រាលី ក្នុងរង្វង់វិស័យកិច្ចបំរើពលរដ្ឋ។ វិស័យនេះមានក្រសួងកិច្ចបំរើពលរដ្ឋ – ដោយមានរួមទាំងអង្គការជំនួយកុមារ (Child Support Agency) និង CRS អូស្ត្រាលី–មេឌីឃែរអូស្ត្រាលី និង Hearing Australia។

វិស័យកិច្ចបំរើពលរដ្ឋគឺអំពីប្រជាពលរដ្ឋ និងកិច្ចបំរើទាំងឡាយដែលពលរដ្ឋអាចត្រូវការនៅជំណាក់កាលផ្សេងៗគ្នានៃជីវិតរបស់គេ។ តួនាទីចំបងនៃវិស័យនេះគឺដើម្បីកែលំអការបង្កើត និងការផ្តល់កិច្ចបំរើទាក់ទិននឹងសង្គម និងសុខភាពរបស់រដ្ឋាភិបាលជូនសាធារណជនអូស្ត្រាលី។

មេឌីឃែរអូស្ត្រាលីផ្តល់បណ្តាកម្មវិធីឧបត្ថម្ភថវិកាសុខភាពសកលរបស់ប្រទេសអូស្ត្រាលី។ កម្មវិធីសុខភាពទាំងឡាយនេះ រួមមាន៖

- មេឌីឃែរ – កម្មវិធីធានារ៉ាប់រងសុខភាពជាសកលរបស់ប្រទេសអូស្ត្រាលី
- គំរោងជំនួយថ្លៃថ្នាំពេទ្យ (Pharmaceutical Benefits Scheme)
- ជំនួយចេញថ្លៃធានារ៉ាប់រងសុខភាពឯកជន 30% របស់រដ្ឋាភិបាលអូស្ត្រាលី
- បញ្ជីចុះឈ្មោះការចាក់ថ្នាំបង្ការរោគកុមារភាពអូស្ត្រាលី (Australian Childhood Immunisation Register)
- បញ្ជីចុះឈ្មោះអ្នកធ្វើអំណោយសរីរាង្គអូស្ត្រាលី (Australian Organ Donor Register)
- កម្មវិធីជំនួយពិសេស (Special Assistance Schemes) (មានរួមទាំងជំនួយពិសេសកោះបាលី ឆ្នាំ២០០៥, ជំនួយក្រុងឡុងដុន, គំរោងជំនួយថែទាំសុខភាពស៊ូណាមី និងបាលីម៉ិដ)
- ការិយាល័យជំនួយគ្រួសារ (Family Assistance Office) ក្នុងភាពជាដៃគូជាមួយស្ថាប័នផ្សេងទៀតទាំងឡាយរបស់រដ្ឋាភិបាលអូស្ត្រាលី

- ពិនិត្យចាត់ចែងដោះស្រាយពាក្យសុំប្រាក់ និងប្រាក់បើកសំរាប់ក្រសួងកិច្ចការអតីតយុទ្ធជន (Department of Veterans' Affairs) (មានរួមទាំងកម្មវិធីជំនួយផ្នែកឱសថសំរាប់មាតុភូមិនិវត្តន៍) ការិយាល័យកិច្ចបំរើផ្នែកសោតវិញ្ញាណ (Office of Hearing Services) និងក្រសួងនៃរដ្ឋអូស្ត្រាលីខាងលិច (Department of Western Australia)។

មេឌីឃែរអូស្ត្រាលីធ្វើការជាដៃគូជាមួយក្រសួងសុខាភិបាល និងការចូលវ័យចំណាស់ ដើម្បីឲ្យសំរេចបាននូវគោលដៅនៃគោលការណ៍សុខភាពរបស់រដ្ឋាភិបាលអូស្ត្រាលី។ សកម្មភាពរបស់យើងធ្វើឡើងក្នុងរង្វង់ក្របខណ្ឌគោលការណ៍របស់រដ្ឋាភិបាល ដែលកំណត់ដោយក្រសួងសុខាភិបាល និងការចូលវ័យចំណាស់ ក្រសួងកិច្ចការអតីតយុទ្ធជន ក្រសួងកិច្ចបំរើគ្រួសារ ទីលំនៅសហគមន៍ និងកិច្ចការជនជាតិដើម ព្រមទាំងច្បាប់ពាក់ព័ន្ធទាំងឡាយ។

លោកអ្នកអាចរកឃើញព័ត៌មានបន្ថែមអំពីមេឌីឃែរអូស្ត្រាលី នៅតាមវ៉ិបសាយរបស់យើង **www.medicareaustralia.gov.au**

## កញ្ចប់ព័ត៌មានដែលបានបកប្រែរួចរបស់មេឌីឃែរអូស្ត្រាលី

យើងមានព័ត៌មានដែលបានបកប្រែរួចសំរាប់កម្មវិធីទាំងឡាយដូចតទៅ:

- មេឌីឃែរ (Medicare)
- គំរោងប្រាក់ជំនួយថ្លៃថ្នាំពេទ្យ (Pharmaceutical Benefits Scheme)
- បញ្ជីចុះឈ្មោះការចាកថ្នាំបង្ការរោគកុមារភាពអូស្ត្រាលី (Australian Childhood Immunisation Register)
- បញ្ជីចុះឈ្មោះអ្នកធ្វើអំណោយសរីរាង្គអូស្ត្រាលី (Australian Organ Donor Register)
- ផែនការមើលថែធ្មេញយុវវ័យរបស់មេឌីឃែរ (Medicare Teen Dental plan)
- កម្មវិធីប្រាក់សំណងថ្លៃសុដន់សិប្បនិម្មិតខាងក្រៅ (External breast prostheses reimbursement program)
- កម្មវិធីជាតិពិនិត្យរកមើលរោគមហារីកពោះវៀន (National Bowel Cancer Screening Program)

យើងក៏មានព័ត៌មានផងដែរអំពី៖

- ការដាក់ពាក្យសុំទាមទារប្រាក់មេឌីឃែរតាមរយៈប្រព័ន្ធអេឡិកត្រូនិក
- ការិយាល័យជំនួយគ្រួសារ
- ការយក ឬផ្ញើថ្នាំពេទ្យ PBS ទៅបរទេស
- ការប្រើថ្នាំពេទ្យដោយសុវត្ថិភាព
- ការធានារ៉ាប់រងសុខភាពអស់មួយជីវិត (ក្រសួងសុខាភិបាល និងការចូលវ័យចំណាស់)។

លោកអ្នកអាចទទួលប័ណ្ណព័ត៌មានទាំងអស់នេះ ពីវ៉ិបសាយរបស់យើង **www.medicareaustralia.gov.au** ឬនៅឯការិយាល័យមេឌីឃែរណាមួយ។

## កិច្ចបំរើអ៊ីនធើណិតរបស់មេឌីឃែរអូស្ត្រាលី

កិច្ចបំរើអ៊ីនធើណិតរបស់មេឌីឃែរអូស្ត្រាលី ធ្វើឲ្យលោកអ្នកងាយស្រួលនឹងបើកអាន កែប្រែព័ត៌មានឲ្យទាន់សភាពការគ្រាសព្វថ្ងៃ និងធ្វើសំណូមពរនូវព័ត៌មាន និងកិច្ចបំរើពីមេឌីឃែរអូស្ត្រាលី។

ដើម្បីប្រើកិច្ចបំរើអ៊ីនធើណិតរបស់យើង លោកអ្នកត្រូវចុះឈ្មោះ និងទទួលពាក្យសម្ងាត់។ ដើម្បីចុះឈ្មោះប្រើកិច្ចបំរើ អ៊ីនធើណិត សូមបើកអាន **www.medicareaustralia.gov.au/online** ឬអញ្ជើញទៅកាន់ការិយាល័យមេឌីឃែរនៅក្បែរលោកអ្នក ហើយត្រូវយកប័ណ្ណមេឌីឃែររបស់លោកអ្នកទៅជាមួយផង។

នៅពេលបានចុះឈ្មោះសំរាប់ប្រើកិច្ចបំរើអ៊ីនធើណិតហើយ លោកអ្នកអាច៖

- សុំប័ណ្ណមេឌីឃែរជំនួសប័ណ្ណចាស់ ឬធ្វើប័ណ្ណដដែលមួយទៀត
- កត់ត្រា និងកែប្រែឲ្យទាន់ពេលនូវព័ត៌មានអំពីគណនីធនាគាររបស់លោកអ្នក
- ពិនិត្យ និងកែប្រែឲ្យទាន់ពេលនូវព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក
- ពិនិត្យការដាក់ពាក្យសុំទាមទារប្រាក់របស់លោកអ្នក ពីមេឌីឃែរកាលពីគ្រាកន្លងមក
- ពិនិត្យតុល្យភាពនៃសំណាញ់សុវត្ថិភាពមេឌីឃែរ (Medicare Safety Net) របស់លោកអ្នក
- ពិនិត្យរបាយការណ៍ប្រាក់បំណាច់ពន្ធដាររមេឌីឃែររបស់លោកអ្នក
- ពិនិត្យរបាយការណ៍អំពីប្រវត្តិនៃការចាក់ថ្នាំបង្ការរោគរបស់កូនលោកអ្នក
- ពិនិត្យព័ត៌មាននៃការចុះឈ្មោះអ្នកធ្វើអំណោយសរីរាង្គរបស់លោកអ្នក។

# ត្រូវការជំនួយដើម្បីឲ្យបានយល់ពីព័ត៌មានរបស់យើងឬទេ?

## សំរាប់អ្នកដែលនិយាយអង់គ្លេសជាភាសាទីពីរ

បើលោកអ្នកត្រូវការព័ត៌មានជាភាសារបស់លោកអ្នកផ្ទាល់ សូមសាកសួរមន្ត្រីមេឌីឃែរ ឬទូរស័ព្ទទៅកាន់**កិច្ចបំរើបកប្រែភាសា (TIS)** តាមលេខ **131 450***។ បន្ទាប់មកលោកអ្នកនឹងត្រូវផ្តល់ឲ្យកិច្ចបំរើនេះនូវលេខទូរស័ព្ទរបស់យើង។ នេះគឺជាកិច្ចបំរើសហគមន៍អូស្ត្រាលី ដែលលោកអ្នកអាចសុំអ្នកបកប្រែជាភាសារបស់លោកអ្នក ដើម្បីជួយក្នុងការសាកសួររបស់លោកអ្នក។ នៅពេលលោកអ្នកកំពុងសួរសំណួរអំពីកិច្ចបំរើរបស់យើង  យើងនឹងបង់ថ្លៃអ្នកបកប្រែភាសាមកពី TIS ។

## សំរាប់អស់អ្នកដែលមានពិការភាពខាងស្តាប់ ឬនិយាយ

បើលោកអ្នកមានពិការភាពខាងស្តាប់ ឬនិយាយ លោកអ្នកអាចទូរស័ព្ទទៅ**កិច្ចបំរើទូរស័ព្ទអង្គុលីលេខ (TTY)** របស់យើងលេខ **1800 552 152****។ ដើម្បីទូរស័ព្ទ TTY របស់យើង លោកអ្នកនឹងត្រូវការប្រើទូរស័ព្ទ TTY។

# ចំពោះព័ត៌មានបន្ថែម

| | |
|---|---|
| វិបសាយ | **www.medicareaustralia.gov.au** |
| អ៊ីមែល | **medicare@medicareaustralia.gov.au** |
| សរសេរទៅ | **Medicare Australia**<br>**GPO Box 9822**<br>នៅក្នុងរដ្ឋធានីរបស់លោកអ្នក |
| ទូរស័ព្ទ | **132 011*** |
| TTY | **1800 552 152**** (សំរាប់អ្នកមានពិការភាពខាងស្តាប់ ឬនិយាយ) |
| TIS | **131 450*** (កិច្ចបំរើបកប្រែភាសាសរសេរ និងនិយាយ) |

*គិតថ្លៃទូរស័ព្ទ។

**គិតថ្លៃទូរស័ព្ទចេញពីទូរស័ព្ទចល័ត និងទូរស័ព្ទដែលត្រូវបង់ថ្លៃសំរាប់ប្រើប៉ុណ្ណោះ។

1577_12a.04.11.09